រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ( គ.ជ.អ.ប )

# ផែនការយុទ្ធសាស្ត្រ

## ស្តីពី

## ការទារគណនេយ្យភាពសង្គម
## សម្រាប់ការអភិវឌ្ឍតាមបែប
## ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

រៀបចំ និងបោះពុម្ពលើកទី៣ដោយ **លេខាធិការដ្ឋាន គ.ជ.អ.ប** ខែកក្កដា ឆ្នាំ២០១៣

# អារម្ភកថា

ការដាក់ចេញនូវគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានបង្ហាញឲ្យឃើញនូវឆន្ទៈដ៏មោះមុតរបស់រាជរដ្ឋាភិបាលកម្ពុជា និងជាការបោះជំហានទៅមុខយ៉ាងសំខាន់មួយក្នុងកិច្ចដំណើរការកំណែទម្រង់អភិបាលកិច្ចថ្នាក់មូលដ្ឋាននៅក្នុងប្រទេសកម្ពុជា សំដៅពង្រឹងលទ្ធិប្រជាធិបតេយ្យ ជំរុញកិច្ចអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចនៅមូលដ្ឋានដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រប្រកបដោយភាពស័ក្តិសិទ្ធិ។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានផ្តល់នូវមូលដ្ឋានគតិយុត្តសម្រាប់កិច្ចដំណើរការកំណែទម្រង់តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយតម្រូវឲ្យបង្កើតក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗតាមរយៈការបោះឆ្នោត ដើម្បីដើរតួនាទីជាអង្គអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅមូលដ្ឋាន។ ក្នុងន័យនេះ ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវមានគណនេយ្យភាពជាចម្បង និងដោយផ្ទាល់ចំពោះប្រជាពលរដ្ឋដើម្បីធានាដល់ការបង្កើននូវតម្លាភាព ជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ និងផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើសម្លេង និងតម្រូវការរបស់ប្រជាពលរដ្ឋទាំងបុរស ស្ត្រី និងក្រុមជនងាយរងគ្រោះនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការវិភាជន៍ ការប្រើប្រាស់ និងការគ្រប់គ្រងធនធាន ព្រមទាំងការផ្តល់សេវាសាធារណៈ សេវារដ្ឋបាល ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចនៅក្នុងមូលដ្ឋានរបស់ខ្លួន។

គណនេយ្យភាពសង្គម គឺជាឧបករណ៍ដ៏មានសារៈសំខាន់ក្នុងការចូលរួមចំណែកដល់ការពង្រឹងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន។ ដោយយល់ឃើញនូវសារៈសំខាន់បែបនេះ គ.ជ.អ.ប បានរៀបចំផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនេះឡើង ដើម្បីធ្វើជាផែនទីបង្ហាញផ្លូវដល់តួអង្គពាក់ព័ន្ធទាំងអស់ក្នុងការអនុវត្តការងារគណនេយ្យសង្គម ក្នុងក្របខ័ណ្ឌនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ផែនការយុទ្ធសាស្ត្រនេះបង្ហាញអំពីចក្ខុវិស័យ គោលបំណង លទ្ធផលរំពឹងទុក គោលការណ៍គន្លឹះ និងក្របខ័ណ្ឌយុទ្ធសាស្ត្រដោយផ្តោតលើយុទ្ធសាស្ត្រសំខាន់ៗចំនួន៥ ដែលត្រូវប្រកាន់យកដោយតួអង្គពាក់ព័ន្ធទាំងអស់ដើម្បីសហការគ្នាអនុវត្តផែនការយុទ្ធសាស្ត្រនេះប្រកបដោយជោគជ័យ។

ក្នុងនាម គ.ជ.អ.ប ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមចំណែកយ៉ាងសកម្មពីតំណាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានាក្នុងការរៀបចំតាក់តែងនូវផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គមនេះ ហើយខ្ញុំក៏មានសេចក្តីសង្ឃឹមជឿជាក់យ៉ាងមុតមាំថា ផ្អែកលើផែនការយុទ្ធសាស្ត្រនេះ គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល

សហគមន៍មូលដ្ឋាន និងប្រជាពលរដ្ឋទាំងឡាយនឹងបន្តសហការគ្នាក្នុងការរៀបចំផែនការសកម្មភាព និងថវិកាលម្អិតសម្រាប់អនុវត្តការងារគណនេយ្យភាពសង្គមនេះ ដើម្បីឈានដល់ការសម្រេចបាននូវគោលបំណងនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិយ៉ាងពិតប្រាកដ។

ទន្ទឹមគ្នានេះដែរ ក្នុងនាម គ.ជ.អ.ប ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះរាល់ការចូលរួមយោបល់ក្នុងន័យស្ថាបនា ដើម្បីកែលំអផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនេះឲ្យកាន់តែមានលក្ខណៈល្អប្រសើរ។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប**

**ស ខេង**

# មាតិកា

**១. សេចក្តីផ្តើម** ........................................ 1
**២. ចក្ខុវិស័យ** ........................................ 2
**៣. គោលបំណង និងលទ្ធផលរំពឹងទុក** ........................................ 2
ក. គោលបំណង ........................................ 2
ខ. លទ្ធផលរំពឹងទុក ........................................ 2
**៤. ក្របខ័ណ្ឌយុទ្ធសាស្ត្រ** ........................................ 4
ក. វិសាលភាព ........................................ 4
ខ. គោលការណ៍នានា ........................................ 7
គ. សារធាតុនានា ........................................ 9
ឃ. យុទ្ធសាស្ត្រ ........................................ 10
**៥. ផែនការសកម្មភាព និងធនធានហិរញ្ញវត្ថុ** ........................................ 20
**៦. សេចក្តីសន្និដ្ឋាន** ........................................ 21
**ឧបសម្ព័ន្ធ ៖** តារាងសង្ខេបអំពីយុទ្ធសាស្ត្រទាំង ៥ និងសកម្មភាព សំខាន់ៗសម្រាប់អនុវត្តយុទ្ធសាស្ត្រទាំងនេះ ........................................ 22

## ១. សេចក្តីផ្តើម

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិបានតម្រូវឲ្យមានការរៀបចំបង្កើត និងដាក់ឲ្យអនុវត្តនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិផ្អែក លើគោលការណ៍នានានៃអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅមូលដ្ឋាន។ គោលការណ៍ដ៏សំខាន់ មួយក្នុងចំណោមគោលការណ៍នានានៃអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅមូលដ្ឋាន គឺគណនេយ្យភាព។

ក្នុងរយៈពេលកន្លងមកនេះ ការពង្រឹងគណនេយ្យភាពក្នុងក្របខ័ណ្ឌ នៃកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវបានផ្តោតជាសំខាន់ទៅលើគណនេយ្យភាពផ្នែកនយោបាយ និងគណនេយ្យភាពផ្នែករដ្ឋបាល។ ដោយឡែក គណនេយ្យភាពសង្គមដែលជាផ្នែកមួយដ៏មានសារៈសំខាន់ នៃគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ឬគណនេយ្យភាពរវាងក្រុមប្រឹក្សាជាប់ឆ្នោតជាមួយប្រជាពលរដ្ឋដែលបានបោះឆ្នោតឲ្យខ្លួន ពុំទាន់ត្រូវបានកំណត់ច្បាស់លាស់សម្រាប់ការអនុវត្តនៅក្រោមក្របខ័ណ្ឌនៃកម្មវិធីជាតិនៅឡើយ។

ដើម្បីបំពេញបន្ថែមទៅនឹងការខ្វះចន្លោះនេះ គ.ជ.អ.ប បានរៀបចំផែនការយុទ្ធសាស្ត្រស្តីពីការងារ គណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនេះឡើង ដោយមានការពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានាដើម្បីកំណត់នូវយុទ្ធសាស្ត្រចាំបាច់ សកម្មភាពជាក់លាក់ និងតួនាទីភារកិច្ចរបស់ស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ក្នុងការចូលរួមចំណែកអនុវត្តការងារគណនេយ្យភាពសង្គម ក្រោមក្របខ័ណ្ឌនៃផែនការយុទ្ធសាស្ត្រដ៏ច្បាស់លាស់មួយ និងដែលមានការឯកភាពគ្នាក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់។

## ២. ចក្ខុវិស័យ

ផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គមនេះ មានចក្ខុវិស័យផ្តោតទៅលើការពង្រឹង ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋ ការលើកកម្ពស់នូវសិទ្ធអំណាចរបស់ប្រជាពលរដ្ឋ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅអនុវត្តកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឲ្យកាន់តែមានប្រសិទ្ធភាព។

## ៣. គោលបំណង និងលទ្ធផលរំពឹងទុក

### ក. គោលបំណង

គណនេយ្យភាពសង្គមក្នុងកិច្ចដំណើរការកំណែទម្រង់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មានគោលបំណងផ្តល់នូវសិទ្ធិអំណាចដល់ប្រជាពលរដ្ឋ សហគមន៍មូលដ្ឋាន ជាពិសេសក្រុមដែលតំណាងឲ្យផលប្រយោជន៍របស់ស្ត្រី យុវវ័យ និងក្រុមជនងាយរងគ្រោះនានា ក្នុងការចូលរួមពង្រឹងការចាត់ចែង ការប្រើប្រាស់ថវិកា និងការផ្តល់សេវាសាធារណៈនៅមូលដ្ឋាន តាមរយៈការលើកកម្ពស់នូវភាពងាយទទួលបានព័ត៌មាន និងការចូលរួមពិនិត្យតាមដានលើការងារថវិកា និងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

### ខ. លទ្ធផលរំពឹងទុក

ការរៀបចំ និងអនុវត្តនូវផែនការយុទ្ធសាស្ត្រ ស្តីពីការងារគណនេយ្យភាពសង្គម នឹងរំពឹងថាទទួលបាននូវលទ្ធផលដូចខាងក្រោម៖

- ✓ ផ្តើមចេញពីលទ្ធផលនៃទំនាក់ទំនងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋ ឬតំណាង នានារបស់ប្រជាពលរដ្ឋនឹងធ្វើឲ្យមាន

ការផ្លាស់ប្តូរ ឬការឆ្លើយតបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះចំពោះប្រជាពលរដ្ឋ

- ✓ សមត្ថភាពរបស់ប្រជាពលរដ្ឋ (ស្ត្រី និងបុរស) និងតំណាងនានារបស់ប្រជាពលរដ្ឋត្រូវបានលើកកម្ពស់កាន់តែប្រសើរឡើង ដើម្បីបន្តចូលរួមផ្តល់យោបល់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ។

ជាមួយគ្នានេះដែរ ផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គមក៏រំពឹងថានឹងរួមចំណែក ផ្តល់នូវផលប្រយោជន៍នានារួមមាន៖

- ✓ ការផ្តល់សេវាកម្ម និងការបែងចែកធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនឹងកាន់តែមានលក្ខណៈប្រកបដោយប្រសិទ្ធភាពតម្លាភាព គណនេយ្យភាព និងសមធម៌
- ✓ សហគមន៍មូលដ្ឋាន និងប្រជាពលរដ្ឋទាំងឡាយ ជាពិសេសស្ត្រី និងយុវវ័យ ដែលជាតួអង្គសំខាន់ក្នុងការចូលរួមចំណែកធ្វើឲ្យមានការផ្លាស់ប្តូរ នឹងត្រូវបានលើកកម្ពស់នូវសិទ្ធិអំណាចរបស់ខ្លួន តាមរយៈការបង្កលក្ខណៈឲ្យពួកគេមានការយល់ដឹងកាន់តែច្រើនឡើងអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់ខ្លួនក្នុងការប្រាស្រ័យទាក់ទងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ
- ✓ មូលធនសង្គម ព្រមទាំងភាពជឿជាក់គ្នាក្នុងចំណោមសមាជិកនានារបស់សហគមន៍ និងរវាងប្រជាពលរដ្ឋជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានបង្កើនឡើង ដែលជាកត្តាជំរុញឲ្យមានការផ្សារភ្ជាប់គ្នារបស់សង្គម និងជាមូលដ្ឋានដ៏សំខាន់ក្នុងការជំរុញទាំងការអភិវឌ្ឍន៍សង្គម និងកំណើនសេដ្ឋកិច្ចមូលដ្ឋាន។

## ៤. ក្របខ័ណ្ឌយុទ្ធសាស្ត្រ

### ក. វិសាលភាព

ផែនការយុទ្ធសាស្ត្រស្ដីពីការងារគណនេយ្យភាពសង្គមនេះ មានវិសាលភាពផ្តោតទៅលើទិដ្ឋភាពទាំងឡាយនៃការធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តសកម្មភាពនៅមូលដ្ឋានប្រកបដោយការចូលរួម នៅក្នុងក្របខ័ណ្ឌនៃដែនសមត្ថកិច្ចនីមួយៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ផែនការនេះក៏រួមមានវិសាលភាពគ្របដណ្តប់ទាំងបញ្ហានានា ដែលពាក់ព័ន្ធនឹងការរៀបចំផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ ការផ្តល់សេវាសង្គម ការបែងចែកធនធាន ព្រមទាំងការរៀបចំតាក់តែង និងអនុវត្តនូវបទប្បញ្ញត្តិនានា។ ដោយសារការធ្វើសេចក្តីសម្រេចចិត្ត និងការផ្តល់សេវាកម្មនានាអាចជះឥទ្ធិពលផ្សេងៗគ្នាទៅលើស្ត្រី និងបុរស អាស្រ័យហេតុនេះ ការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គម ចាំបាច់ត្រូវយកចិត្តទុកដាក់ទៅលើបញ្ហាយេនឌ័រផងដែរ។

គណនេយ្យភាពសង្គម គឺជាដំណើរការនៃការផ្សារភ្ជាប់ទំនាក់ទំនងដ៏ល្អប្រសើររវាងប្រជាពលរដ្ឋ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយវាក៏ជាមធ្យោបាយមួយដែលបន្សុីគ្នារវាងគោលការណ៍ទាំងឡាយ នៃអភិបាលកិច្ចដែលក្នុងនោះរាល់ការធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តសកម្មភាពជាសាធារណៈនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានប្រកាន់យកតាមកិច្ចដំណើរការនេះ។ ជាទូទៅ កិច្ចដំណើរការនេះរួមមាននូវរាល់សកម្មភាពទាំងឡាយណាដែលផ្តល់ឱកាសឲ្យប្រជាពលរដ្ឋ និងតំណាងរបស់ខ្លួនអាចការពារនូវផលប្រយោជន៍របស់ខ្លួន និងពិនិត្យតាមដានលើការបំពេញការងាររបស់ក្រុមប្រឹក្សា មន្ត្រីរដ្ឋបាល និងអ្នកផ្តល់សេវាកម្មនានាដែលជាអ្នកអនុវត្ត

សេចក្តីសម្រេចចិត្តទាំងឡាយពាក់ព័ន្ធទៅនឹងសិទ្ធិ បទប្បញ្ញត្តិ ធនធាន និង ការផ្តល់សេវាកម្មនៅមូលដ្ឋាន។

ផែនការយុទ្ធសាស្ត្រនេះ ក៏នឹងបន្ថែមនូវគុណតម្លៃទៅលើគណនេយ្យភាពផ្នែកនយោបាយ និងគណនេយ្យភាពផ្នែករដ្ឋបាលផងដែរ។ ដោយសារផែនការយុទ្ធសាស្ត្រនេះនឹងបង្កើតឲ្យមានយន្តការនានា ដែលធ្វើឲ្យប្រជាពលរដ្ឋអាចមានលទ្ធភាពប្រាស្រ័យទាក់ទងដោយផ្ទាល់ ជាមួយក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលនានា អាស្រ័យហេតុនេះ ផែនការយុទ្ធសាស្ត្រនេះក៏នឹងរួមចំណែកដល់ការពង្រឹងកិច្ចដំណើរការអភិបាលកិច្ចជាទូទៅ ឲ្យកាន់តែមានភាពប្រសើរឡើងផងដែរ។ ជារួម គណនេយ្យភាពសង្គមមានភាពខុសគ្នាពីគណនេយ្យផ្នែកនយោបាយ និងគណនេយ្យផ្នែករដ្ឋបាលត្រង់ថា គណនេយ្យភាពសង្គមត្រូវបានប្រព្រឹត្តទៅតាមរយៈ ការប្រាស្រ័យទាក់ទងគ្នាដោយផ្ទាល់រវាងប្រជាពលរដ្ឋ (ឬតំណាងរបស់ខ្លួន) ជាមួយក្រុមប្រឹក្សា មន្ត្រីរដ្ឋបាល និងអ្នកផ្តល់សេវាកម្មនានា។ ទោះបីជាក្រុមប្រឹក្សាជាអ្នកកំណត់នូវទិសដៅអភិវឌ្ឍន៍របស់មូលដ្ឋានមួយក៏ដោយ ក៏គណនេយ្យភាពសង្គម និងគណនេយ្យភាពនយោបាយនឹងជំរុញឲ្យក្រុមប្រឹក្សានៅតែរក្សាការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋជាប់ជានិច្ច។

គណនេយ្យភាពសង្គមតម្រូវឲ្យមានការរៀបចំនូវយន្តការនានា នៃការប្រាស្រ័យទាក់ទងដ៏ច្បាស់លាស់ និងមានប្រសិទ្ធភាពរវាងតួអង្គចំនួនពីរក្រុមពោលគឺក្រុមប្រជាពលរដ្ឋ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវឆ្លើយតប និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ។

- ✓ ក្រុមប្រជាពលរដ្ឋ គឺសំដៅទៅលើតួអង្គមិនមែនរដ្ឋដែលត្រូវមានការអភិវឌ្ឍសមត្ថភាពឲ្យ បានគ្រប់គ្រាន់។ ជារួម អង្គការមិនមែនរដ្ឋាភិបាល សហគមន៍មូលដ្ឋាន និងផ្នែកឯកជននៅថ្នាក់មូលដ្ឋាន

មានតួនាទីយ៉ាងសំខាន់ក្នុងការធានាឲ្យមានការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋនៅក្នុងកិច្ចដំណើរការអភិបាលកិច្ចមូលដ្ឋាន។ អង្គការសង្គមស៊ីវិលគឺជាមធ្យោបាយមួយដែលអាចជំរុញ និងបង្កើតឡើងនូវកិច្ចដំណើរការជាសមូហភាពនៃការចូលរួម របស់ប្រជាពលរដ្ឋ។ ដោយឡែកក្រុមប្រជាពលរដ្ឋនានា ជាពិសេសក្រុមដែលតំណាងឲ្យផលប្រយោជន៍របស់ស្ត្រី យុវវ័យ និងក្រុមជនងាយរងគ្រោះនានា ក៏រួមចំណែកជួយគាំទ្រដល់ស្ត្រី យុវវ័យ និងក្រុមជនងាយរងគ្រោះ ឲ្យមានតួនាទីចូលរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញការងារគណនេយ្យភាពសង្គមឲ្យទទួលបានជោគជ័យផងដែរ។

- ✓ រដ្ឋបាលថ្នាក់ក្រោមជាតិនានាដែលមានលក្ខណៈឆ្លើយតប និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ គឺសំដៅទៅលើរដ្ឋបាលដែលត្រូវបំពេញការងារប្រកបដោយសមត្ថភាព និងមានលទ្ធភាពអាចកំណត់បានអំពីតម្រូវការ និងអាទិភាពផ្សេងៗគ្នារបស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងមូលដ្ឋានរបស់ខ្លួន ក្នុងនោះរាប់បញ្ចូលទាំងតម្រូវការរបស់ស្ត្រី បុរស យុវវ័យ ជនជាតិដើមភាគតិច និងក្រុមជនងាយរងគ្រោះនានាផងដែរ។ រដ្ឋបាលទាំងនេះមិនត្រឹមតែមានភាពជាតំណាងតាមលក្ខណៈប្រជាធិបតេយ្យ តាមរយៈការបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋ ដើម្បីធ្វើសេចក្តីសម្រេចចិត្តជាសាធារណៈ និងត្រួតពិនិត្យតាមដានការអភិវឌ្ឍនានាប៉ុណ្ណោះនោះទេ ប៉ុន្តែរដ្ឋបាលទាំងនេះក៏ត្រូវបានផ្តល់នូវឆន្ទានុសិទ្ធិក្នុងការវិភាជន៍ប្រភពធនធាន និងមធ្យោបាយនានា ព្រមទាំងអំណាចក្នុងការអនុវត្តនូវសេចក្តីសម្រេចចិត្តប្រកបដោយការចូលរួមផងដែរ។

ជារួមការអភិវឌ្ឍន៍នូវទំនាក់ទំនងរវាងតួអង្គទាំងពីរក្រុមខាងលើនេះ គឺជាស្នូលនៃកិច្ចដំណើរការគណនេយ្យភាពសង្គម។ នីតិវិធី និងយន្តការនានា

នៃការរៀបចំជាបែបផែននៃទំនាក់ទំនងគ្នានេះ នឹងកំណត់អំពីរបៀបធ្វើអន្តរាគមន៍ទៅលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តកិច្ចដំណើរការគណនេយ្យភាពសង្គម។ ប្រសិទ្ធភាពនៃយន្តការទាំងនេះ គឺអាស្រ័យទៅលើកត្តាផ្សេងៗមួយចំនួនទៀត ពោលគឺការរៀបចំបែបផែននានាដែលធានាឲ្យមានការចូលរួមការទទួលបាននូវព័ត៌មាន និងការកំណត់បានអំពីតម្រូវការដែលមានលក្ខណៈផ្សេងៗគ្នានៅមូលដ្ឋាន។ ជាការពិតណាស់ ដើម្បីធ្វើឲ្យរដ្ឋបាលមូលដ្ឋាន មានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ គឺអាស្រ័យជាសំខាន់ទៅលើការធ្វើឲ្យប្រជាពលរដ្ឋមានលទ្ធភាព ងាយទទួលបាននូវព័ត៌មាននានាពាក់ព័ន្ធទៅនឹងការបំពេញកិច្ចការជាសាធារណៈ និងការធ្វើសេចក្តីសម្រេចចិត្តទាំងឡាយរបស់រដ្ឋបាលមូលដ្ឋាន។

## ខ. គោលការណ៍នានា

ការរៀបចំតាក់តែង និងការអនុវត្តផែនការយុទ្ធសាស្ត្រនេះផ្តើមចេញពីគោលការណ៍សំខាន់ៗចំនួន ៧ ដូចខាងក្រោម៖

**ទីមួយ៖ អាទិភាពរបស់ប្រជាពលរដ្ឋ**

ប្រជាពលរដ្ឋជាអ្នកកំណត់អំពីតម្រូវការជាអាទិភាពរបស់ខ្លួន។ តម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋអាចផ្តោតទៅលើសេវាអប់រំ សុខាភិបាល ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន កសិកម្ម ។ល។

**ទីពីរ៖ កម្រិតមូលដ្ឋាន**

សកម្មភាពនានានឹងផ្តោតទៅលើការប្រាស្រ័យទាក់ទង ការពិភាក្សា និងការដោះស្រាយបញ្ហានានានៅតែក្នុងកម្រិតមូលដ្ឋានប៉ុណ្ណោះ ។

**ទីបី៖ ការចូលរួមក្នុងន័យស្ថាបនា**

គណនេយ្យភាពសង្គម នឹងប្រកាន់យកនូវអភិក្រមដែលមានលក្ខណៈស្ថាបនាដោយផ្អែកទៅលើកិច្ចសហការគ្នាជាជាងការប្រឈមមុខគ្នា ដើម្បីឈានទៅសម្រេចនូវលទ្ធផលដែលប្រាថ្នាចង់បាន។

**ទីបួន៖ ការតាំងចិត្ត**

រដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរ អង្គភាពជំនាញនៅថ្នាក់ក្រោមជាតិត្រូវតាំងចិត្តចូលរួមយ៉ាងសកម្ម នូវរាល់សកម្មភាពគណនេយ្យភាពសង្គមជាមួយប្រជាពលរដ្ឋ និងតំណាងនានារបស់ប្រជាពលរដ្ឋ។

**ទីប្រាំ៖ ភាពជាដៃគូ**

កិច្ចខិតខំប្រឹងប្រែងនានា នឹងត្រូវបានប្រកាន់យកយ៉ាងច្បាស់លាស់ ដើម្បីកសាង និងពង្រឹងភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល និងក្នុងចំណោមអង្គការសង្គមស៊ីវិលនានា។

**ទីប្រាំមួយ៖ ការដាក់បញ្ចូលនូវតម្រូវការនានា**

អន្តរាគមន៍នានាត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើ ការផ្តល់សិទ្ធិអំណាច ការចូលរួម និងការដោះស្រាយនូវរាល់តម្រូវការផ្សេងៗគ្នារបស់ប្រជាពលរដ្ឋទាំងឡាយ ក្នុងនោះរាប់បញ្ចូលទាំងតម្រូវការរបស់ស្រ្តី យុវវ័យ និងក្រុមជនងាយរងគ្រោះនានា ដូចជាជនក្រីក្រ និងជនជាតិដើមភាគតិចជាដើមផងដែរ។

**ទីប្រាំពីរ៖ ការខិតខំលុបបំបាត់នូវគម្លាត**

ផែនការយុទ្ធសាស្រ្តនេះ នឹងដោះស្រាយភាពចន្លោះប្រហោងមួយចំនួននៃការចូលរួមរបស់ប្រជាពលរដ្ឋ ព្រមទាំងមានគោលបំណងធ្វើឲ្យមានការផ្លាស់ប្តូរនូវវិសាលភាព និងសារធាតុនៃការប្រាស្រ័យទាក់ទងរវាងប្រជាពលរដ្ឋ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

## គ. សារធាតុនានា

ដោយសារគណនេយ្យភាពសង្គម ត្រូវបានកើតឡើងតាមរយៈការផ្សារភ្ជាប់គ្នារវាងប្រជាពលរដ្ឋ និងរដ្ឋបាលថ្នាក់ក្រោមជាតិ អាស្រ័យហេតុនេះ វាតម្រូវឲ្យមានការយកចិត្តទុកដាក់ទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការដែលជាសារធាតុដ៏សំខាន់នៃគណនេយ្យភាពសង្គម ព្រមទាំងការបង្កើតនូវយន្តការនានាដើម្បីផ្សារភ្ជាប់ និងគាំទ្រដល់ផ្នែកទាំងពីរនេះ។

- ✓ **ផ្នែកតម្រូវការ៖** រួមមានប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលដែលប្រើប្រាស់នូវឧបករណ៍នានានៃគណនេយ្យភាពសង្គម ដើម្បីចូលរួមប្រកបដោយភាពស្ថាបនាជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នផ្ដល់សេវាកម្មនានា សំដៅលើកម្ពស់ការបំពេញមុខងាររបស់ស្ថាប័នទាំងនេះ។
- ✓ **ផ្នែកផ្គត់ផ្គង់៖** ពាក់ព័ន្ធទៅនឹងតួនាទីរបស់តួអង្គរដ្ឋនៅក្នុងក្របខ័ណ្ឌគណនេយ្យភាពសង្គម។ ថ្នាក់ជាតិមានតួនាទីក្នុងការសម្របសម្រួលការងារគណនេយ្យភាពសង្គម តាមរយៈការរៀបចំបង្កើតឲ្យមានកិច្ចដំណើរការ វិធាន ស្តង់ដារ និងលិខិតបទដ្ឋានគតិយុត្តនានា។ ដោយឡែក រដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នផ្ដល់សេវាកម្មនានាជាអ្នកប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ និងតំណាងរបស់ប្រជាពលរដ្ឋ។
- ✓ **ការគាំទ្រដល់ផ្នែកទាំងពីរនេះ៖** រួមមានការរៀបចំជាយន្តការនានាដែលត្រូវបានដាក់ឲ្យដំណើរការ ដើម្បីផ្សារភ្ជាប់ទំនាក់ទំនងរវាងប្រជាពលរដ្ឋជាមួយនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ឃ. យុទ្ធសាស្ត្រ

ដើម្បីសម្រេចបានគោលបំណងខាងលើនេះ ក្របខ័ណ្ឌគណនេយ្យភាពសង្គមរួមមានយុទ្ធសាស្ត្រជាចម្បងចំនួន៥ ដូចខាងក្រោម៖

**យុទ្ធសាស្ត្រទីមួយ៖** ការលើកកម្ពស់តម្លាភាព និងភាពងាយទទួលបាននូវព័ត៌មានអំពីស្តង់ដារ ថវិកា និងការបំពេញការងារ។

**យុទ្ធសាស្ត្រទីពីរ** ៖ ការសម្របសម្រួលឲ្យមានការត្រួតពិនិត្យ តាមដានរបស់ប្រជាពលរដ្ឋលើសកម្មភាព និងការផ្តល់សេវាកម្មមូលដ្ឋាន របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**យុទ្ធសាស្ត្រទីបី** ៖ ការលើកកម្ពស់សមត្ថភាពយល់ដឹង របស់ប្រជាពលរដ្ឋអំពីថវិកា។

**យុទ្ធសាស្ត្រទីបួន** ៖ ការគាំទ្រដល់តួអង្គនានា និងការកសាងសមត្ថភាពដល់តួអង្គទាំងនេះដើម្បី សម្របសម្រួលការចូលរួមរបស់ប្រជាពលរដ្ឋ និងកិច្ចដំណើរការនានានៃគណនេយ្យភាពសង្គម។

**យុទ្ធសាស្ត្រទីប្រាំ៖** ការប្រមូលមេរៀន បទពិសោធន៍ដែលបានមកពីអន្តរាគមន៍នានានៅមូលដ្ឋាន ដើម្បីប្រែក្លាយបទពិសោធន៍ទាំងនេះ ដាក់បញ្ចូលទៅក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងពង្រឹងការងារអង្គការសង្គមស៊ីវិលនានា។

# យុទ្ធសាស្ត្រទី ១
# ការលើកកម្ពស់តម្លាភាព និងភាពងាយទទួលបាននូវព័ត៌មាន អំពីស្តង់ដារ ថវិកា និងការបំពេញការងារ

ព័ត៌មាន គឺជាឧបករណ៍ដ៏សំខាន់ក្នុងការជំរុញឲ្យមានការចូលរួមរបស់ប្រជាពលរដ្ឋយ៉ាងពិតប្រាកដ។ ជាមួយគ្នានេះដែរ ការពិភាក្សា និងពិគ្រោះយោបល់គ្នាក៏ចាំបាច់ត្រូវផ្អែកលើមូលដ្ឋានច្បាស់លាស់ នៃព័ត៌មានទិន្នន័យ និងភស្តុតាងនានាផងដែរ។ អាស្រ័យហេតុនេះ ប្រសិនបើគ្មានព័ត៌មាននោះទេ ប្រជាពលរដ្ឋក៏ពុំអាចមានលទ្ធភាពចូលរួមជួយពង្រឹង និងកែលំអការបំពេញកិច្ចការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិបានដែរ។

ក្នុងន័យនេះ លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួង ស្ថាប័នផ្សេងៗទៀតនឹងសហការគ្នារៀបចំតាក់តែងកម្មវិធី ដែលមានគោលដៅជាក់លាក់ស្តីពីសកម្មភាពដែលផ្តោតទៅលើការពង្រឹងការផ្សព្វផ្សាយជាសាធារណៈ នូវព័ត៌មានដែលប្រជាពលរដ្ឋងាយទទួលបាន។ ព័ត៌មានទាំងនេះរួមមានដូចជាស្តង់ដារ ថវិកា និងការបំពេញការងារក្នុងការផ្តល់សេវាកម្ម។ រដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានពង្រឹងសមត្ថភាពឲ្យមានការយល់ដឹង និងអនុវត្តនូវល័ក្ខខ័ណ្ឌនានានៃការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ។ សេចក្តីណែនាំនានានឹងត្រូវផ្តោតទៅលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ✓ តើព័ត៌មានអ្វីខ្លះដែលត្រូវផ្តល់ដល់អ្នកណា?
- ✓ តើត្រូវរៀបចំទម្រង់ផ្តល់ព័ត៌មានបែបណាឲ្យមានលក្ខណៈសាមញ្ញដើម្បីធានាឲ្យប្រជាពលរដ្ឋងាយយល់ដឹងអំពីព័ត៌មានទាំងនោះ?
- ✓ តើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីឲ្យព័ត៌មានទាំងនោះអាចងាយរក និងទទួលបាន? ឧទាហរណ៍ អំពីមធ្យោបាយផ្សព្វផ្សាយនានាដែលរួមមាន ក្តារព័ត៌មាន ខិតប័ណ្ណ កិច្ចប្រជុំជាសាធារណៈ អ៊ិនធឺណិត សារព័ត៌មាន វិទ្យុ ទូរទស្សន៍។ល។

- ✓ ប្រសិនបើមានលទ្ធភាព តើត្រូវធានាយ៉ាងណាដើម្បីធ្វើឲ្យទិន្នន័យព័ត៌មានអាចរៀបចំឡើង ដោយមានការបែងចែកអំពីភេទយ៉ាងច្បាស់លាស់?
- ✓ តើត្រូវធ្វើយ៉ាងណាដើម្បីធានាឲ្យមានគណនេយ្យភាពក្នុងការផ្តល់ព័ត៌មាន? (អ្នកណា/អង្គភាពណាជាអ្នកទទួលខុសត្រូវដោយផ្ទាល់ក្នុងការផ្តល់ព័ត៌មាន និងទណ្ឌកម្មនានាដែលត្រូវដាក់ពិន័យក្នុងករណីដែលព័ត៌មានទាំងនោះពុំត្រូវបានផ្តល់គ្រប់គ្រាន់)

រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពនានាដែលផ្តល់សេវាកម្មនៅមូលដ្ឋានត្រូវផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ អំពីស្តង់ដារនៃការផ្តល់សេវាកម្មដោយរៀបរាប់អំពីកម្រិត និងគុណភាពនៃសេវាកម្មដែលត្រូវផ្តល់ ព្រមទាំងត្រូវបិទផ្សាយនូវព័ត៌មានអំពីស្តង់ដារទាំងនេះ រួមទាំងថវិកា និងការចំណាយនានានៅតាមសាលាឃុំ សង្កាត់ ក្រុង ស្រុក មណ្ឌលសុខភាព និងសាលារៀនទាំងឡាយ។ល។ លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួង ស្ថាប័នពាក់ព័ន្ធនានាត្រូវសហការគ្នារៀបចំសេចក្តីណែនាំដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពផ្តល់សេវាកម្មនៅមូលដ្ឋាន អំពីទម្រង់បែបផែននៃការផ្តល់ព័ត៌មានដែលមានលក្ខណៈងាយស្រួលយល់ដល់ប្រជាពលរដ្ឋ។

ទោះបីជាព័ត៌មានទាំងនោះនឹងត្រូវបានផ្តល់ក្នុងទម្រង់បែបផែន ដែលងាយស្រួលក្នុងការស្វែងរក និងទទួលបានក៏ដោយ ក៏ចាំបាច់ត្រូវមានការគាំទ្រដល់ប្រជាពលរដ្ឋ ជាពិសេសក្រុមជនងាយរងគ្រោះនានាក្នុងការប្រើប្រាស់នូវព័ត៌មានទាំងនោះផងដែរ។ អង្គការសង្គមស៊ីវិលនានានឹងត្រូវបានគាំទ្រក្នុងការធ្វើការជាមួយស្ត្រី បុរស យុវវ័យ និងក្រុមប្រជាពលរដ្ឋផ្សេងទៀត ដើម្បីធានាថា ទាំងស្ត្រី បុរស យុវវ័យ និងក្រុមប្រជាពលរដ្ឋផ្សេងទៀតអាចទទួលបានការយល់ដឹង និងអាចមានសមត្ថភាពក្នុងការប្រើប្រាស់ព័ត៌មានទាំងនោះដើម្បីចូលរួមចំណែកផ្តល់យោបល់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

# យុទ្ធសាស្ត្រទី ២
# ការសម្របសម្រួលឲ្យមានការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ នៅលើសកម្មភាព និងការផ្តល់សេវាកម្មមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

យុទ្ធសាស្ត្រនេះ ផ្តោតជាសំខាន់ទៅលើការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការត្រួតពិនិត្យតាមដាន និងការផ្តល់យោបល់លើការបំពេញកិច្ចការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ មានន័យថា កិច្ចដំណើរការត្រួតពិនិត្យតាមដាននេះ ត្រូវបានផ្តួចផ្តើមដោយក្រុមប្រជាពលរដ្ឋនានានៅមូលដ្ឋាន ដែលជាយន្តការដោយឡែកមួយ មិនស្ថិតនៅក្នុងយន្តការនៃការចូលរួមរបស់ប្រជាពលរដ្ឋដែលត្រូវបានបង្កើតឡើងមានលក្ខណៈជាកាតព្វកិច្ចនោះឡើយ។ ការសម្របសម្រួលឲ្យប្រជាពលរដ្ឋមានតួនាទីយ៉ាងសកម្មក្នុងការត្រួត ពិនិត្យតាមដាននេះនឹងផ្តល់លទ្ធភាពធ្វើឲ្យមានការឆ្លុះបញ្ចាំង អំពីលទ្ធផលនៃការបំពេញការងារប្រៀបធៀបទៅនឹងស្តង់ដារនានា ព្រមទាំងការកំណត់បាននូវជំហាននានាដែលរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពផ្តល់សេវាកម្មមូលដ្ឋាននានាត្រូវប្រកាន់យកដើម្បីពង្រឹង និងកែលំអដល់ការបំពេញការងាររបស់ខ្លួន។ ជាមួយគ្នានេះដែរ ការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ ទៅលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពផ្តល់សេវាកម្មនានាក៏នឹងផ្តល់លទ្ធភាពឲ្យស្ត្រី យុវវ័យ និងប្រជាពលរដ្ឋទាំង ឡាយក្នុងមូលដ្ឋានទទួលបានព័ត៌មានដើម្បីផ្តល់យោបល់នៅក្នុងកិច្ចដំណើរការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគសម្រាប់ឆ្នាំបន្ទាប់ផងដែរ។

ពាក់ព័ន្ធនឹងបញ្ហានេះ កិច្ចដំណើរការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋតម្រូវឲ្យមានការចូលរួមយ៉ាងច្បាស់លាស់ ពីអ្នកពាក់ព័ន្ធនានា មានន័យថា ព័ត៌មានទាំងឡាយដែលពាក់ព័ន្ធនឹងការបំពេញការងារប្រចាំឆ្នាំដូចជាអំពីស្តង់ដារ ថវិកា និងការចំណាយ និងលទ្ធផលរំពឹងទុកជាដើមរបស់

រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពផ្តល់សេវាកម្មនានាត្រូវតែបង្ហាញជូនក្នុងកិច្ចដំណើរការត្រួតពិនិត្យតាមដានដែលរៀបចំឡើងដោយប្រជាពលរដ្ឋ។ កិច្ចដំណើរការនេះនឹងត្រូវបានរៀបចំឡើង ដើម្បីធានាឲ្យមានការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋទាំងឡាយ ជាពិសេសការចូលរួមដែលមានលក្ខណៈស្មើភាពគ្នារបស់ស្ត្រី យុវវ័យ និងក្រុមជនងាយរងគ្រោះទាំងឡាយ។ នៅក្នុងករណីខ្លះ រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាអ្នកផ្តល់សេវាកម្មដោយផ្ទាល់ ក៏ប៉ុន្តែក្នុងករណីខ្លះទៀត រដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទីត្រឹមតែជាអ្នកសម្របសម្រួល ជំរុញ និងគាំទ្រលើការផ្តល់សេវាកម្មទាំងនោះតែប៉ុណ្ណោះ។ អាស្រ័យហេតុនេះ នៅក្នុងកិច្ចដំណើរការប្រាស្រ័យទាក់ទងជាមួយអង្គភាពផ្តល់សេវាកម្មនានា នឹងធ្វើឲ្យតួនាទីសម្របសម្រួល ជំរុញ និងគាំទ្ររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានលើកកម្ពស់កាន់តែប្រសើរឡើងជាលំដាប់។ មានន័យថា រដ្ឋបាលថ្នាក់ក្រោមជាតិនឹងក្លាយជាស្ពានតភ្ជាប់ការប្រាស្រ័យទាក់ទងរវាងប្រជាពលរដ្ឋ និងអង្គភាពជំនាញនានា ដែលផ្តល់សេវាកម្មនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

ជាមួយគ្នានេះដែរ វិសាលភាពនៃការត្រួតពិនិត្យតាមដាននេះចាំបាច់ត្រូវបង្កលក្ខណៈឲ្យស្ត្រី យុវវ័យ និងប្រជាពលរដ្ឋទាំងឡាយអាចមានលទ្ធភាពក្នុងការចូលរួមផ្តល់យោបល់ ទៅលើបញ្ហានានាដែលជាក្តីកង្វល់បំផុតរបស់ខ្លួន។

ដោយឡែក ឧបករណ៍ចាំបាច់មួយចំនួនគប្បីត្រូវបានយកមកប្រើប្រាស់ដើម្បីធានាដល់កិច្ចដំណើរការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ។ ក្នុងស្ថានភាពបច្ចុប្បន្ននេះ សហគមន៍មូលដ្ឋាននានា អាចមានតួនាទីយ៉ាងសំខាន់នៅក្នុងការរៀបចំឲ្យមានកិច្ចដំណើរការត្រួតពិនិត្យ តាមដានប្រចាំឆ្នាំរបស់សហគមន៍ទៅលើបញ្ហាដែលមានលក្ខណៈជាអន្តរវិស័យ ដើម្បីផ្តល់លទ្ធភាពឲ្យប្រជាពលរដ្ឋមានការយល់ដឹងអំពីចំណុចខ្លាំង និងចំណុចខ្សោយ

នៃការផ្តល់សេវាកម្មពាក់ព័ន្ធនានា។ តាមរយៈកិច្ចដំណើរការនេះ សហគមន៍នានាអាចនឹងមានលទ្ធភាពឈានទៅដល់ការត្រួតពិនិត្យតាមដាន ដែលមានលក្ខណៈកាន់តែស៊ីជម្រៅ ទៅលើវិស័យជាក់លាក់មួយចំនួននាពេលអនាគត ដូចជា វិស័យសុខាភិបាល និងអប់រំជាដើម។

## យុទ្ធសាស្ត្រទី ៣
## ការលើកកម្ពស់សមត្ថភាពយល់ដឹងរបស់ប្រជាពលរដ្ឋ
## អំពីថវិកា

យុទ្ធសាស្ត្រនេះ ផ្តោតជាសំខាន់ទៅលើការគាំទ្ររបស់អង្គការសង្គមស៊ីវិលក្នុងការលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីការបែងចែក ការចាត់ចែង ការប្រើប្រាស់ និងការគ្រប់គ្រងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ គួបផ្សំជាមួយនឹងការលើកកម្ពស់តម្លាភាព នៃការងារថវិកាដូចបានចែងនៅក្នុងយុទ្ធសាស្ត្រទី១ កិច្ចខិតខំប្រឹងប្រែងគាំទ្រពីអង្គការសង្គមស៊ីវិលនឹងជួយពង្រឹងដល់ការស្វែងរកនូវព័ត៌មានពាក់ព័ន្ធនឹងហិរញ្ញវត្ថុ (ចំណូល និង ចំណាយ) ព្រមទាំងជួយលើកកម្ពស់ដល់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពផ្តល់សេវាកម្មពាក់ព័ន្ធនានា។ ការចូលរួមគាំទ្រពីអង្គការសង្គមស៊ីវិល មិនត្រឹមតែជួយលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីការងារថវិកា ដើម្បីអាចចូលរួមត្រួតពិនិត្យលើការងារគ្រប់គ្រងហិរញ្ញវត្ថុប៉ុណ្ណោះនោះទេ ប៉ុន្តែក៏ជាការជួយលើកកម្ពស់នូវការយល់ដឹងរបស់ប្រជាពលរដ្ឋ ដើម្បីមានលទ្ធភាពចូលរួមក្នុងការកំណត់អាទិភាពនៃតម្រូវការនានា និងផ្តល់យោបល់ដល់ការបែងចែកមូលនិធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

ដើម្បីពង្រឹងដល់ការងារថវិកា ចាំបាច់ត្រូវរៀបចំឲ្យមាននីតិវិធីសាស្ត្រប្រកបដោយកិច្ចសហប្រតិបត្តិការគ្នាយ៉ាងច្បាស់លាស់។ តួអង្គរដ្ឋត្រូវរៀបចំនូវសេចក្តីណែនាំអំពីទម្រង់ដ៏សាមញ្ញ ស្តីពីការងារគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ក្រុមប្រឹក្សា។ ដោយឡែក តួអង្គមិនមែនរដ្ឋត្រូវចូលរួមផ្តល់យោបល់អំពីបទពិសោធន៍ដែលអាចអនុវត្តបានជាក់ស្តែងនៅមូលដ្ឋាន។ ផ្អែកលើកិច្ចសហការគ្នានេះ ទម្រង់ និងកិច្ចដំណើរការដ៏ច្បាស់លាស់មួយដែលត្រូវប្រើប្រាស់សម្រាប់ការបែងចែកមូលនិធិ និងរបាយការណ៍ស្តីពីការប្រើប្រាស់មូលនិធិនឹងត្រូវបានដាក់បញ្ចូលទៅក្នុងលិខិតបទដ្ឋានគតិយុត្ត។ ជាមួយគ្នានេះដែររដ្ឋបាលថ្នាក់ក្រោមជាតិក៏ចាំបាច់ត្រូវបានពង្រឹងសមត្ថភាព អំពីការប្រើប្រាស់នូវទម្រង់ និងអំពីការអនុវត្តនូវកិច្ចដំណើរការទាំងនេះផងដែរ។

## យុទ្ធសាស្ត្រទី ៤
## ការគាំទ្រដល់តួអង្គនានា និងការកសាងសមត្ថភាព ដល់តួអង្គទាំងនេះ ដើម្បីសម្របសម្រួលការចូលរួមរបស់ប្រជាពលរដ្ឋ និងកិច្ចដំណើរការនានា នៃគណនេយ្យភាពសង្គម

ដើម្បីជំរុញឲ្យមានការប្រាស្រ័យទាក់ទង រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព ចាំបាច់តម្រូវឲ្យមានកិច្ចអន្តរាគមន៍ដល់ក្រុមប្រជាពលរដ្ឋទាំងក្នុងការបង្កើត និងការជួយគាំទ្រដល់ក្រុមប្រជាពលរដ្ឋទាំងនេះ។ ការបង្កើតឡើងនូវក្រុមប្រជាពលរដ្ឋ គឺជាមធ្យោបាយដ៏សំខាន់ មួយសំដៅធានាដល់ការបញ្ចេញមតិយោបល់ និងលើកឡើងនូវតម្រូវការអាទិភាពនានារបស់ប្រជាពលរដ្ឋ។ អាស្រ័យហេតុនេះ ការពង្រឹងសមត្ថភាពរបស់ក្រុមប្រជាពលរដ្ឋ ក្នុងការប្រាស្រ័យទាក់ទងជាមួយរដ្ឋបាលថ្នាក់

ក្រោមជាតិ គឺជាយុទ្ធសាស្ត្រគន្លឹះមួយក្នុងការលើកកម្ពស់យន្តការនៃការចូលរួមរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានក្នុងកិច្ចដំណើរការគណនេយ្យភាពសង្គម។

ពាក់ព័ន្ធនឹងកិច្ចការនេះ ចាំបាច់ត្រូវធានាឲ្យមានការជួយគាំទ្រផ្នែកបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីមានសមត្ថភាពក្នុងការផ្តួចផ្តើមគំនិតសម្រាប់រៀបចំ និងអនុវត្តនូវសកម្មភាពនានាពាក់ព័ន្ធនឹងគណនេយ្យភាពសង្គម។ មន្ត្រីសំខាន់ៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ត្រូវបានអភិវឌ្ឍសមត្ថភាពក្នុងការពិភាក្សា និងសហការជាមួយតួអង្គមិនមែនរដ្ឋនានាដើម្បីលើកកម្ពស់ការងារគណនេយ្យភាពសង្គម និងរបៀបរបបធ្វើការងារជាមួយសហគមន៍មូលដ្ឋាន និងអង្គការសង្គមស៊ីវិលនានាឲ្យកាន់ តែមានប្រសិទ្ធភាព។

ជាមួយគ្នានេះដែរ ការប្រាស្រ័យទាក់ទងគ្នានេះក៏ចាំបាច់ត្រូវមានការជួយគាំទ្រពីតួអង្គមិនមែនរដ្ឋក្នុងការសម្របសម្រួល និងការអនុវត្តនូវសកម្មភាពនានានៃការងារគណនេយ្យភាពសង្គមផងដែរ។ អាស្រ័យហេតុនេះ ការកសាងសមត្ថភាពរបស់តួអង្គមិនមែនរដ្ឋដើម្បីបំពេញតួនាទីដ៏សំខាន់នេះ ក៏ចាំបាច់ត្រូវបានផ្តោតការយកចិត្តទុកដាក់ផងដែរ។ ផែនការសកម្មភាពលម្អិតមួយ នឹងត្រូវបានរៀបចំឡើងដោយរាប់បញ្ចូលទាំងការកំណត់អំពី តួនាទីជាក់លាក់នានារបស់តួអង្គមិនមែនរដ្ឋ និងតម្រូវការនានាក្នុងការជួយគាំទ្រដល់ការអភិវឌ្ឍន៍សមត្ថភាពដល់តួអង្គមិនមែនរដ្ឋទាំងឡាយ ដើម្បីមានលទ្ធភាពបំពេញតួនាទីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

## យុទ្ធសាស្ត្រទី ៥
## ការប្រមូលមេរៀន បទពិសោធន៍ដែលបានមកពីអន្តរាគមន៍នានានៅមូលដ្ឋាន ដើម្បីផ្សព្វផ្សាយបទពិសោធន៍ទាំងនេះដាក់បញ្ចូលទៅក្នុងគោលនយោបាយរបស់ រាជរដ្ឋាភិបាល និងការពង្រឹងការងារអង្គការសង្គមស៊ីវិលនានា

ផ្អែកលើសកម្មភាពផ្តួចផ្តើមជាបឋម នៃការងារគណនេយ្យភាពសង្គមនៅមូលដ្ឋាននេះ ចាំបាច់ត្រូវមានការសិក្សាអំពីមេរៀន និងបទពិសោធន៍ដែលទទួលបានជោគជ័យ និងមិនទទួលបានជោគជ័យ ព្រមទាំងធានាថាមេរៀន និងបទពិសោធន៍ទាំងនោះត្រូវបានផ្សព្វផ្សាយ ចែករំលែក និងធ្វើឲ្យមានការយល់ដឹងជាសាធារណៈយ៉ាងទូលំទូលាយ។ យុទ្ធសាស្ត្រនេះពិតជាមានសារៈសំខាន់ក្នុងការគាំទ្រ ដល់យុទ្ធសាស្ត្រផ្សេងៗទៀតដែលបានរៀបរាប់ខាងលើ។ ផ្អែកតាមមេរៀន និងពិសោធន៍ដែលបានដកស្រង់ចេញពីការអនុវត្តន៍ជាក់ស្តែងក្នុងជំហានដំបូងនេះ ត្រូវធានាថាគំនិតផ្តួចផ្តើមសាមញ្ញនានា ដែលបានប្រើប្រាស់ប្រកបដោយជោគជ័យនៅក្នុងស្ថានភាពរបស់សហគមន៍ជាក់លាក់ណាមួយត្រូវបានលើកកម្ពស់ និងអាចមានលទ្ធភាពយកទៅអនុវត្តនៅកន្លែងដទៃទៀត ព្រមទាំងត្រូវធានាថា រាល់គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងតម្លាភាព និងគណនេយ្យភាពត្រូវមានលក្ខណៈឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា និងអាចអនុវត្តបានដោយជោគជ័យ។

ការបង្កឲ្យមានបរិយាកាសសម្រាប់ការសិក្សារៀនសូត្រពីមេរៀន និងបទពិសោធន៍នៃការអនុវត្តន៍ ពិតជាមានសារៈសំខាន់បំផុតក្នុងការធ្វើអន្តរាគមន៍ដល់ការងារគណនេយ្យភាពសង្គម។ ពាក់ព័ន្ធនឹងបញ្ហានេះចាំបាច់ត្រូវមានការរៀបចំឲ្យបែបផែននៃការសិក្សារៀនសូត្រ ការត្រួតពិនិត្យតាមដាន

របស់អង្គការសង្គមស៊ីវិល និងការផ្តួចផ្តើមឲ្យមាននូវការរៀបចំជាវេទិការួមគ្នារវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលដើម្បីឆ្លុះបញ្ចាំង និងផ្តល់យោបល់កែលំអទៅលើគោលនយោបាយ និងការអនុវត្តន៍នានាពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គម។ ជារួម គ.ជ.អ.ប ត្រូវធ្វើការសម្រេចចិត្តអំពីរបៀបនៃការគ្រប់គ្រង និងលើកកម្ពស់នូវមូលដ្ឋានគ្រឹះនៃសកម្មភាពគណនេយ្យភាពសង្គម និងត្រូវអនុម័តអំពីវិធីសាស្រ្តមួយសម្រាប់ការសិក្សាដកស្រង់បទពិសោធន៍។

ដើម្បីធានាដល់ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃទៅលើលទ្ធផលរំពឹងទុកនានា ចាំបាច់ត្រូវរៀបចំនូវបែបផែននៃការត្រួតពិនិត្យ តាមដាន និងវាយតម្លៃដ៏ទូលំទូលាយមួយ ដោយយកចិត្តទុកដាក់ទៅលើបញ្ហាមួយចំនួនដូចខាងក្រោម៖

- ✓ ការត្រួតពិនិត្យ តាមដានលើការអនុវត្តន៍ត្រូវពិនិត្យទៅលើអង្គភាព បុគ្គល ពេលវេលា និងការចំណាយដែលពាក់ព័ន្ធនឹងការធ្វើអន្តរាគមន៍នានា។
- ✓ ការត្រួតពិនិត្យ តាមដានលើលទ្ធផលរំពឹងទុកដោយឡែក ស្តីពីបញ្ហាយេនឌ័រ ត្រូវពិនិត្យទៅលើស្ថានភាពនៃការផ្លាស់ប្តូរដ៏ច្បាស់លាស់មួយសម្រាប់ទាំងស្រ្តី និងបុរសក្នុងក្របខ័ណ្ឌសកម្មភាពនានានៃការងារគណនេយ្យភាពសង្គម។
- ✓ ការវាយតម្លៃត្រូវពិនិត្យទៅលើ លទ្ធផលនៃការងារគណនេយ្យភាពសង្គម ដែលធ្វើឲ្យមានការផ្លាស់ប្តូរនូវសិទ្ធិអំណាច អភិបាលកិច្ចសមធម៌សង្គម និងការផ្តល់សេវាកម្មក្នុងសហគមន៍។ សូចនាករនានានៃចំណុចខាងលើទាំងនេះ គប្បីត្រូវបានប្រមូលចងក្រងជា

ទិន្នន័យទាំងពេលមុន និងពេលក្រោយធ្វើអន្តរាគមន៍នៃការងារគណនេយ្យភាពសង្គម។

លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវសហការជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធនានាដើម្បីធានាដល់ការប្រមូលចងក្រងមេរៀន និងបទពិសោធន៍នានា និងត្រូវធានាដល់ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រ ស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនេះ។

## ៥. ផែនការសកម្មភាព និងធនធានហិរញ្ញវត្ថុ

ដើម្បីធានាដល់ការបង្កើតបាននូវលទ្ធផលរំពឹងទុក និងសម្រេចបាននូវគោលបំណងនៃផែនការយុទ្ធសាស្ត្រនេះ ភាគីពាក់ព័ន្ធនានាត្រូវរៀបចំនូវផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់ការអនុវត្តផ្អែកតាមយុទ្ធសាស្ត្រនានាដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រនេះ។ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវធានាថា ផែនការសកម្មភាព និងថវិកាសម្រាប់គាំទ្រដល់តួអង្គរដ្ឋត្រូវបានរៀបចំ និងត្រូវបានដាក់បញ្ចូលនៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប។

ជាមួយគ្នានេះដែរ លេខាធិការដ្ឋាន គ.ជ.អ.ប ក៏ត្រូវខិតខំសហការជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា ដើម្បីគាំទ្រដល់ការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់គាំទ្រដល់ផ្អែកតម្រូវការនៃផែនការយុទ្ធសាស្ត្រនេះ ដែលត្រូវអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធនានា។

## ៦. សេចក្តីសន្និដ្ឋាន

ការរៀបចំ និងដាក់ចេញឲ្យអនុវត្តនូវផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គមនេះគឺជាការឆ្លុះបញ្ចាំងឲ្យឃើញនូវឆន្ទៈដ៏មោះមុតរបស់រាជរដ្ឋាភិបាល ក្នុងការបន្តជំរុញកិច្ចដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ផែនការយុទ្ធសាស្ត្រនេះនឹងបំពេញនូវការខ្វះចន្លោះនានា ក្នុងការកំណត់នូវយុទ្ធសាស្ត្រចាំបាច់សម្រាប់ការអនុវត្តការងារគណនេយ្យភាពសង្គម ដែលជាគោលការណ៍ដ៏មានសារៈសំខាន់មួយនៃអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅមូលដ្ឋាន។

ជាមួយគ្នានេះដែរ ការរៀបចំ និងដាក់ចេញនូវផែនការយុទ្ធសាស្ត្រនេះក៏បានបង្ហាញនូវកិច្ចខិតខំប្រឹងប្រែងសហការគ្នា ក្នុងភាពជាដៃគូប្រកបដោយភាពស្ថាបនារវាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលក្នុងការគាំទ្រដល់ការអនុវត្តនូវផែនការយុទ្ធសាស្ត្រដ៏មានសារៈសំខាន់នេះ។

ផែនការយុទ្ធសាស្ត្រនេះ នឹងក្លាយទៅជាផែនទីបង្ហាញផ្លូវដ៏មានសារៈសំខាន់សម្រាប់ភាគីពាក់ព័ន្ធ នានា និងជាមូលដ្ឋានគ្រឹះនៃការរៀបចំផែនការសកម្មភាព និងថវិកាលម្អិត និងកម្មវិធីអន្តរាគមន៍ជាក់លាក់នានារបស់ភាគីពាក់ព័ន្ធទាំងឡាយ។ ការអនុវត្តដោយជោគជ័យនូវផែនការយុទ្ធសាស្ត្រនេះនឹងចូលរួមចំណែកយ៉ាងធំធេង ក្នុងការសម្រេចបាននូវគោលបំណងនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សំដៅជំរុញកិច្ចអភិវឌ្ឍមូលដ្ឋាន កែលំអការផ្តល់សេវាសាធារណៈ និងសេវារដ្ឋបាលនានាដោយមានការចូលរួមតាមលក្ខណៈប្រជាធិបតេយ្យ តម្លាភាព គណនេយ្យភាព ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រប្រកបដោយភាពស័ក្តិសិទ្ធិ។

## ឧបសម្ព័ន្ធ
## តារាងសង្ខេបអំពីយុទ្ធសាស្ត្រទាំង ៥ និងសកម្មភាពសំខាន់ៗសម្រាប់អនុវត្តយុទ្ធសាស្ត្រទាំងនេះ

| យុទ្ធសាស្ត្រ | សកម្មភាពរបស់ក្រុមប្រជាពលរដ្ឋ/អង្គការសង្គមស៊ីវិល | សកម្មភាពរបស់រាជរដ្ឋាភិបាល |
|---|---|---|
| **១. ព័ត៌មាន** ៖ លើកកម្ពស់តម្លាភាព និងលទ្ធភាពទទួលបានព័ត៌មានអំពីស្តង់ដារសេវា ថវិកា និងការបំពេញការងារ | • កសាងចំណេះដឹង និងជួយគាំទ្រឲ្យប្រជាពលរដ្ឋមានការយល់ដឹង និងមានលទ្ធភាពទទួលបានព័ត៌មានពីរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែប្រសើរឡើង។ | • រៀបចំលិខិតបទដ្ឋាន និងកិច្ចដំណើរការស្តីពីការផ្សព្វផ្សាយព័ត៌មាន ជាសាធារណៈដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរ ការិយាល័យ ជំនាញ<br>• ពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិនានាដើម្បីឲ្យមានការយល់ដឹង និងអនុវត្តនូវល័ក្ខខ័ណ្ឌនានាក្នុងការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ<br>• ជំរុញការអនុវត្ត និងត្រួតពិនិត្យការអនុវត្តនូវល័ក្ខខ័ណ្ឌនានានៃការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ |
| **២. ការតាមដានត្រួតពិនិត្យ** ៖ បង្កើតយន្តការតាមដាន និងការធ្វើរបាយការណ៍របស់ប្រជាពលរដ្ឋទៅលើសកម្មភាពនានា និងការផ្តល់សេវាកម្មនៅមូលដ្ឋាន | • រៀបចំឱ្យមានការតាមដាន ត្រួតពិនិត្យជាប្រចាំរបស់សហគមន៍លើសកម្មភាពនានា និងការផ្តល់សេវាកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• បង្កលទ្ធភាពឲ្យប្រជាពលរដ្ឋ និងក្រុមប្រឹក្សារដ្ឋ | • រៀបចំបង្កើត និងពង្រឹងឧបករណ៍នានាសម្រាប់ការងារត្រួតពិនិត្យតាមដានរបស់ថ្នាក់ជាតិ<br>• រៀបចំ និងផ្សព្វផ្សាយជាសាធារណៈនូវស្តង់ដានៃការផ្តល់សេវាកម្ម សាធារណៈដោយមានកិច្ចសហការ |

| | | |
|---|---|---|
| | បាលថ្នាក់ ក្រោមជាតិមានលទ្ធភាពតាមដានត្រួតពិនិត្យទៅលើការផ្តល់សេវាកម្មនៅមូលដ្ឋានរបស់មន្ទីរ ការិយាល័យជំនាញ (ដូចជាសេវាសុខភាព អប់រំ ទឹកស្អាត និងការគ្រប់គ្រងធនធានធម្មជាតិ) | ជាមួយប្រជាពលរដ្ឋ<br>• ដាក់បញ្ចូលនូវយន្តការ និងនីតិវិធីត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋឲ្យទៅជាផ្នែកមួយនៃផែនការ ប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ ក្រោមជាតិ<br>• រៀបចំ និងបង្កើតនូវមុខងារ និងនីតិវិធីស្តីពីការត្រួតពិនិត្យមើលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទៅលើការផ្តល់សេវាកម្មនានានៅមូលដ្ឋាន |
| **៣.ការងារថវិកា៖** លើកកម្ពស់ការយល់ដឹង និងការស្វែងយល់របស់ប្រជាពលរដ្ឋអំពីការងារថវិកា | • អនុវត្តកម្មវិធីនានាដើម្បីលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីការងារថវិការដ្ឋបាលថ្នាក់ក្រោមជាតិ<br>• រៀបចំ និងអនុវត្តនូវការវិភាគអំពីការងារថវិកាប្រកបដោយការចូលរួម | • រៀបចំទម្រង់ឯកសារដែលមានលក្ខណៈសាមញ្ញសម្រាប់ក្រុមប្រឹក្សាក្នុងការបំពេញព័ត៌មានអំពីការគ្រប់គ្រងហិរញ្ញវត្ថុ ផែនការថវិកា និងការចំណាយនានា និងដើម្បីពង្រឹងនូវភាពងាយស្រួលដល់ប្រជាពល រដ្ឋក្នុងការទទួលបានព័ត៌មានទាំងនេះ<br>• រៀបចំបង្កើត និងដាក់បញ្ចូលយន្តការ និងនីតិវិធីត្រួតពិនិត្យហិរញ្ញវត្ថុរបស់ប្រជាពលរដ្ឋឲ្យទៅជាផ្នែកមួយនៃផែនការប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |

| | | |
|---|---|---|
| **៤.ការផ្សារភ្ជាប់ទំនាក់ទំនង៖** ជំរុញការផ្សារភ្ជាប់ទំនាក់ទំនងរវាងតួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋ ព្រមទាំង កសាងសមត្ថភាពនានាដើម្បីសម្របសម្រួលទំនាក់ទំនងនេះ | • ផ្សារភ្ជាប់ទំនាក់ទំនង និងកសាងសមត្ថភាពអង្គការមិនមែនរដ្ឋាភិបាលដើម្បីគាំទ្រសកម្មភាពក្នុងយុទ្ធសាស្ត្រទាំងបីខាងលើ | • អភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ (ឧទាហរណ៍ មន្ត្រីសម្របសម្រួល ឬគាំទ្រការអភិវឌ្ឍន៍សហគមន៍) ដើម្បីគាំទ្រដល់ក្រុមប្រជាពលរដ្ឋនានា និងកំណត់បាននូវអង្គការមិនមែនរដ្ឋាភិបាលនានាដែលត្រូវចូលរួមក្នុងសកម្មភាពនេះ |
| **៥.ការសិក្សាពីមេរៀន និងបទពិសោធន៍៖** ស្វែងយល់ និងប្រមូលបទពិសោធន៍ដែលបានមកពីអន្តរាគមន៍នានានៅមូលដ្ឋានដើម្បីបញ្ចូលទៅក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងលើកកម្ពស់ការអនុវត្តរបស់អង្គការសង្គមស៊ីវិល | • រៀបចំពីបែបផែននៃការសិក្សាមេរៀនបទពិសោធន៍ និងការត្រួតពិនិត្យ តាមដានរបស់អង្គការសង្គមស៊ីវិល<br>• សម្របសម្រួល និងកំណត់អាទិភាពនូវកម្មវិធីត្រួតពិនិត្យ តាមដានដែលមានលក្ខណៈសកម្ម | • រៀបចំវេទិកានានា ដើម្បីឆ្លុះបញ្ចាំង និងផ្តល់យោបល់ត្រឡប់ទៅលើការអនុវត្តជាក់ស្តែង ព្រមទាំងពិចារណាលើយោបល់ទាំងនេះដើម្បីដាក់បញ្ចូល ទៅក្នុងការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានា។ សម្របសម្រួលនូវម្មវិធីត្រួតពិនិត្យ តាមដានដែលមានលក្ខណៈសកម្ម។ |